មើលសេចក្តីជូនដំណឹងនេះជាភាសាខ្មែរ អេស្ប៉ាញ និងព័រទុយហ្គាល់នៅលើទំព័រដែលបានភ្ជាប់។

# សេចក្តីជូនដំណឹង

## លោកអ្នកមានបណ្តឹងនៅក្នុងប្រព័ន្ធតុលាការនៃរដ្ឋ **Rhode Island**។

## លោកអ្នកមានសិទ្ធិស្នើសុំអ្នកបកប្រែដោយឥតគិតថ្លៃសម្រាប់ខ្លួនឯង។

ដីកាប្រតិបត្តិរបស់តុលាការកំពូលនៃ Rhode Island (Rhode Island Supreme Court Executive Order) លេខ 2012-05 បានចែងថានៅពេលបុគ្គលដែលមានចំណេះដឹងផ្នែកភាសាអង់គ្លេសមានកំណត់ (LEP) បង្ហាញខ្លួននៅក្នុងតុលាការ តុលាការនៃ Rhode Island នឹងផ្តល់អ្នកបកប្រែដែលបានអនុញ្ញាតដោយឥតគិតថ្លៃសម្រាប់ចុងចោទ ដើមចោទ សាក្សី ជនរងគ្រោះ មាតាបិតារបស់អនីតិជន ឬនរណាម្នាក់ដែលពាក់ព័ន្ធយ៉ាងសំខាន់នៅក្នុងដំណើរការតុលាការ។ សេវាកម្មបកប្រែនេះ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃសម្រាប់គូភាគី និងនៅគ្រប់ប្រភេទនៃបណ្តឹង ទាំងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ អ្នកបកប្រែក្នុងតុលាការធ្វើការនៅក្នុងគ្រប់តុលាការទាំងអស់របស់ប្រព័ន្ធតុលាការនៃរដ្ឋ Rhode Island។

**ដើម្បីគ្រោងពេលវេលាអ្នកបកប្រែសម្រាប់ថ្ងៃចូលសវនាការរបស់លោកអ្នក លោកអ្នកមានជម្រើសដូចខាងក្រោម ៖**

1. **ទូរស័ព្ទមកកាន់ការិយាល័យអ្នកបកប្រែប្រចាំតុលាការតាមរយៈលេខ (401) 222-8710 ឬ**
2. **ផ្ញើអ៊ីម៉ែលទៅកាន់ interpreterfeedback@courts.ri.gov ឬ**
3. **ទៅកាន់ការិយាល័យអ្នកបកប្រែដើម្បីគ្រោងពេលវេលាអ្នកបកប្រែ ៖**

**The Office of Court Interpreters**
**Licht Judicial Complex**
**Fourth Floor, Room 401**
**250 Benefit Street**
**Providence, RI 02903**

**នៅពេលស្នើសុំអ្នកបកប្រែ សូមផ្តល់នូវព័ត៌មានដូចខាងក្រោម ៖**

- **ឈ្មោះ និងលេខបណ្តឹងរបស់លោកអ្នក**
- **ភាសាដែលលោកអ្នកស្នើសុំ**
- **កាលបរិច្ឆេទ និងម៉ោងសវនាការរបស់លោកអ្នក**
- **ទីតាំងនៃសវនាការរបស់លោកអ្នក**
- **ឈ្មោះ និងលេខទូរស័ព្ទលោកអ្នកដែលយើងខ្ញុំអាចទំនាក់ទំនងលោកអ្នក ឬមេធាវីលោកអ្នកបាន**

---

សម្រាប់ព័ត៌មានបន្ថែមជាភាសាព័រទុយហ្គាល់ រុស្ស៊ី និងអេស្ប៉ាញ រួមទាំងបញ្ជីទម្រង់បែបបទតុលាការដែលមានជាភាសាអេស្ប៉ាញនោះ សូមចូលទៅកាន់គេហទំព័រយើងខ្ញុំនៅលើអ៊ិនធឺណិត ៖

https://www.courts.ri.gov/Interpreters/englishversion/Pages/default.aspx.

ដើម្បីស្នើសុំការបកប្រែសេចក្តីជូនដំណឹងនេះជាភាសាណាមួយផ្សេងទៀត សូមទូរស័ព្ទមកការិយាល័យអ្នកបកប្រែប្រចាំតុលាការតាមរយៈលេខ (401) 222-8710។ វាជាការចាំបាច់ដែលត្រូវមានអ្នកនិយាយភាសាអង់គ្លេសជាមួយលោកអ្នកនៅពេលដែលលោកអ្នកទូរស័ព្ទចូល។

តុលាការ Rhode Island ប្តេជ្ញាធ្វើឲ្យតុលាការអាចប្រើប្រាស់បានសម្រាប់មនុស្សគ្រប់គ្នា។